**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

**លេខ: ២០៦៨ លស.អគ**

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩

**សូមជម្រាបជូន**

**ឯកឧត្តម លោកជំទាវ អគ្គនាយករដ្ឋបាល**

**គ្រប់ក្រសួងរដ្ឋលេខាធិការដ្ឋាន និងស្ថាប័នរដ្ឋ**

**កម្មវត្ថុ** : ករណីលិខិតបទដ្ឋានគតិយុត្តិ ដែលស្នើឆ្លងទីស្ដីការគណៈរដ្ឋមន្ត្រី ជា Soft Copy ។

**យោង** : -លិខិតលេខ ៨២៧ សជណ.អគ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ របស់ ទីស្ដីការគណៈរដ្ឋមន្ត្រី

-សារាចរណែនាំលេខ០១ សរណន ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៩ ស្ដីពីការប្រើប្រាស់កម្រងកម្មវិធីពុម្ពអក្សរខ្មែរយូនីកូដ (Khmer-Unicode) របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។

សេចក្ដីដូចមានចែងក្នុងកម្មវិធី និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន ឯកឧត្តម លោកជំទាវ ជ្រាបថា :ដើម្បីឱ្យមានលក្ខណៈងាយស្រួល និងឯកភាពគ្នាលើពុម្ពអក្សរ (Font) Computer នោះអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាលស្នើសុំរាល់លិខិតបទដ្ឋានគតិយុត្តិទាំងអស់ ដែលត្រូវស្នើសុំដាក់ប្រជុំនៅទីស្ដីការគណៈរដ្ឋមន្ត្រី សូមវាយអក្សរខ្មែរយូនីកូដ (Khmer-Unicode) វិញដើម្បី ឱ្យដំណើរការផ្លាស់ប្ដូរពុម្ពអក្សរ (Font) នេះមានភាពរលូនឆាប់រហ័ស និងអនុវត្តឱ្យបានស៊ីចង្វាក់គ្នា ។ ចំពោះការផ្លាស់ប្ដូរវាយពុម្ពអក្សរខ្មែរយូនីកូដ (Khmer-Unicode) នេះ អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាលសូមកំណត់រយៈពេលឱ្យតែ៦០ថ្ងៃប៉ុណ្ណោះ សម្រាប់ក្រសួង-ស្ថាប័នទាំងអស់ធ្វើការរៀបចំ គិតចាប់ពីថ្ងៃនៃការជូនដំណឹងនេះ ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ មេត្តាសហការចំពោះការផ្លាស់ប្ដូរពុម្ពអក្សរខ្មែរយូនីកូដ (Khmer-Unicode) វិញ ក្នុងករណីមានការលំបាកលើបញ្ហាបច្ចេកទេសសូមធ្វើការទំនាក់ទំនងជាមួយ NiDA ដើម្បីជួយសម្រួល ។

សូមឯកឧត្តម លោកជំទាវ មេត្តាទទួលនូវការរាប់អានអំពីខ្ញុំ ។

**ទីប្រឹក្សារាជរដ្ឋាភិបាល** និងជា **អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

ចម្លងជូន :

-អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា (NiDA)

-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន

-គ្រប់អាជ្ញាធរនិងអង្គភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី

-ឯកសារ-កាលប្បវត្តិ